# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីពុទ្ធភាសិតមួយបទក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនា

Website: www.hoksavann.org

ថ្ងៃទី៣១ តុលា ២០០៤

គាថាមួយបទនៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនាពោលថា នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ ឯវំ គោបេថ អត្តានំ ខណោ វោ មា ឧបច្ចគា ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ប្រែថា អ្នកទាំងឡាយចូរគ្រប់គ្រងខ្លួន ឲ្យដូចជាគេថែរក្សាការពារទឹកដីនគរ ដែលតាំងនៅជាយដែន ទាំងខាងក្នុងទាំងខាងក្រៅយ៉ាងនោះឯង ។ ខណៈចូរកុំកន្លងនូវអ្នកទាំងឡាយឡើយ ព្រោះបុគ្គលទាំងឡាយដែលមានខណៈកន្លងហួសទៅហើយ រមែងសោកស្តាយហើយតែងសោកសៅនៅក្នុងនរក ។

ពាក្យថា អ្នកទាំងឡាយចូរគ្រប់គ្រងខ្លួន បានសេចក្តីថា ត្រូវអប់រំចិត្ត ឲ្យស្ថិតនៅក្នុងកុសលធម៌ជានិច្ច ដោយសមថៈវិបស្សនា បិទបាំងរាំងរាកុំ ឲ្យអកុសលចូលមកក្នុងចិត្តបាន ដោយសេចក្តីព្យាយាមបួនយ៉ាង គឺនេះ បាបដែលកើតមានហើយ ខាឃាំងកុំឲ្យបានថ្មីចូលក្នុងចិត្តបាន កុសលណាដែលកើតមានហើយ ត្រូវរក្សាទុក ប្រៀបផ្ទៀបការគ្រប់គ្រងចិត្ត ដូចជាគេដែលរក្សាការពារទឹកដីនគរ ដែលស្ថិតនៅជាយដែន ព្រោះនៅជាយដែនជាជនបទស្ថិតនៅដាច់ស្រយាលពីទីក្រុង តែងមានចោរប្រព្រឹត្តធ្វើអំពើចោរកម្មលួចប្លន់ធ្វើបាបអ្នកស្រុក ។ មួយទៀត នៅជាយដែនរវាងប្រទេសនីមួយៗ តែងមានបញ្ហាព្រំប្រទល់ដែន ដូចជាប្រទេសកម្ពុជា តែងចោទប្រទេសជិតខាងទាំងពីរ គឺប្រទេសវៀតណាមនិងប្រទេសថៃ ថាបានរំលោភឈ្លានពានប្រទេសកម្ពុជា ដោយការបង្ខិតព្រំប្រទល់ដែន ចូលមកក្នុងដីនៃប្រទេសកម្ពុជា ។ ដូច្នេះហើយបានជាប្រទេសនីមួយៗ តែងតែរក្សាការពារព្រំប្រទល់ដែនរៀងៗខ្លួន ។ មធ្យោបាយការពារព្រំប្រទល់ដែនមានវិធីច្រើនយ៉ាង បើដីគោក គេចាត់ឲ្យតាំងប៉មយាម ។ បើមានព្រៃមានភ្នំនោះជារបងធម្មជាតិប្រសើរណាស់ ត្រូវព្រមព្រៀងកំណត់ដោយប្រទេសដែលជាប់នឹងព្រំដែន ។ វិធីមួយទៀត គឺការធ្វើផ្លូវថ្នល់ ព័ទ្ធជុំវិញព្រំប្រទល់ដែន ។ ពិសេស ការការពារព្រំប្រទល់ដែនឲ្យបានច្រើន ដើម្បីសំរេចបំណងនេះ រដ្ឋត្រូវធ្វើផ្លូវគមនាគមន៍ គឺផ្លូវថ្នល់ទាក់ទងពីទីក្រុងមកព្រំប្រទល់ដែន បង្កើតផ្សារ បង្កើតសាលារៀន បង្កើតវត្ត ដោះស្រាយបញ្ហាទឹក រក្សាសន្តិសុខជាដើម នោះប្រជាពលរដ្ឋនឹងទៅរស់នៅទីនោះច្រើន ទុកជារបងការពារព្រំដែនកុំឲ្យប្រទេសជិតខាងរំកិលព្រំដែន ។ ក្រៅពីនោះ ត្រូវមានសន្ធិសញ្ញារវាងប្រទេសដែលនៅជាប់ព្រំប្រទល់គ្នា ដោយទទួលស្គាល់ព្រំដែនរៀងខ្លួនចំពោះគោលសីមា ដែលបានបោះយ៉ាងជាក់លាក់មួយ ដោយទទួលស្គាល់ពីអង្គការអន្តរជាតិផង ។ បើព្រំប្រទល់ជាប់ដោយដែនសមុទ្រ គេយាមល្បាតដោយកប៉ាល់ឬកាណូតរហូតយាមល្បាតដោយយន្តហោះម្តងម្កាលផង, ប្រសិនបើព្រំប្រទល់តែងមានបញ្ហានឹងគ្នា ។

ពាក្យនៃគាថានោះបន្តថា បុគ្គលទាំងឡាយដោលមានខណៈកន្លងទៅហើយ តែងមានការសោយសោកនោះ បានសេចក្តីថា ពេលវេលាកន្លងទៅពុំបានបំពេញកិច្ចការដែលជាប្រយោជន៍ខ្លួននិងប្រយោជន៍សង្គមរបស់ខ្លួន ដោយការធ្វេសប្រហែស ។ ព្រះពុទ្ធជាម្ចាស់សំដែងថា ពេលវេលាកន្លងទៅ អាយុជីវិតរបស់សព្វសត្វក៏ប្រព្រឹត្តទៅមុខដែរ គឺទៅកាន់ការចាស់ជរារហូតដល់ស្លាប់ ។ ដូច្នេះបើបានបំពេញកិច្ចការងារល្អជាប្រយោជន៍ហើយ បើពេលវេលាកន្លងទៅ ក៏មិននឹកស្តាយក្រោយ ព្រោះបានបំពេញកិច្ចជាប្រយោជន៍ហើយ ។ ព្រះពុទ្ធសាសនាមិនឲ្យមនុស្សដេកចាំសំណាងឡើយ គឺកើតមកត្រូវតែបំពេញការងារ គឺការងារល្អសុចរិត យុត្តិធម៌ ។ បើទុកជាដឹងថា មានសំណាងបានកសាងពីជាតិមុនក៏ដោយ ក៏ត្រូវតែប្រឹងប្រែងព្យាយាមធ្វើការងារក្នុងបច្ចុប្បន្ននេះទៀត ទើបសំណាងនោះចេញឲ្យផលបាន ។ មនុស្សម្នាក់ៗត្រូវសាងខ្លួនឯង ឲ្យមានវិជ្ជាសម្បត្តិ ចរិយាសម្បត្តិ និងគុណធម៌មានមេត្តាធម៌ជាដើម ដោយការសិក្សារៀនសូត្រ និងការអប់រំចិត្ត ។ ចំពោះអាជ្ញាធរខ្មែរដែលជាបុគ្គលសាធារណៈ ត្រូវធ្វើកិច្ចការងារឲ្យបានត្រឹមត្រូវតាមមុខងារដែលរដ្ឋប្រគល់ឲ្យ ដើម្បីធ្វើឲ្យប្រទេសកម្ពុជាមានការរីកចំរើនលូតលាស់ បំបាត់អំពើហឹង្សា បំបាត់ភាពក្រីក្រជាដើម ។ ប្រទេសកម្ពុជាបានខាតពេលវេលាអស់ជាង៣០ឆ្នាំ ព្រោះមានវិបត្តិនយោបាយ ការទាស់ទែងខ្វែងគំនិតគ្នា បានធ្វើឲ្យប្រទេសកម្ពុជាវិនាសអន្តរាយគ្រប់វិស័យ ទាំងទ្រព្យសម្បត្តិជាតិ ទាំងធនធានមនុស្ស ។ តទៅមុខទៀត ជនជាតិកម្ពុជាគ្រប់រូប ត្រូវទុកអតីតកាលជាមេរៀន កុំដើរតាមគន្លងចាស់នេះ ហើយធ្វើកិច្ចការឲ្យបានល្អ ស្របតាមពុទ្ធភាសិតខាងដើមថា កុំឲ្យពេលវេលាកន្លងទៅដោយពុំបានបំពេញការងារល្អ ជាប្រយោជន៍ខ្លួននិងប្រយោជន៍សង្គមរបស់ខ្លួនឡើយ ។៚